មាត្រា ៦.- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួង និងស្ថាប័នដែលមានកិច្ចពាក់ព័ន្ធ និងគណៈកម្មការត្រូវអនុវត្ត អនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# ២-សេចក្តីសំរេច

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៥០ សសរ

## ស្តីពីការលុបចោលរោងចក្រអារឈើ និងរោងម៉ាស៊ីន អារឈើ នៅទូទាំងប្រទេស

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៥ ក្រច. ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រង វិស័យព្រៃឈើ

-បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-យោងតាមគោលការណ៍អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

## សំរេច

ប្រការ ១ ៈ លុបចោលនូវរាល់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មព្រៃឈើ និងរោងម៉ាស៊ីនអារឈើ ដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស្ថាប័ន និងអាជ្ញាធរដែនដីបានអនុញ្ញាតកន្លងមក ។

**ប្រការ ២ :** អនុញ្ញាតអោយបន្តសុពលភាពប្រកបអាជីវកម្មរោងចក្រអារឈើ ផលិតក្តារបន្ទះ និងកែច្នៃឈើរបស់ក្រុមហ៊ុនចំរុះរដ្ឋ ឬ របស់ក្រុមហ៊ុនវិនិយោគទុនដែលមានព្រៃសម្បទានស្របច្បាប់ ដោយត្រូវបំពាក់បន្ថែមមធ្យោបាយកែច្នៃទំនើប ដើម្បីបង្កើនតម្លៃបន្ថែមនៃឈើ និងបង្កើនការងារជូនប្រជាពលរដ្ឋ ។

**ប្រការ ៣ :** ចំពោះសហគ្រាសវិនិយោគរោងចក្រ រោងសិប្បកម្មកែច្នៃផលិតគ្រឿងសង្ហារឹម និងវត្ថុសិល្បៈអំពីឈើ និងអនុផលព្រៃឈើសំរាប់បំរើការនាំចេញ និងការប្រើប្រាស់ចាំបាច់ក្នុងប្រទេស និងដេប៉ូលក់ឈើ ត្រូវបានរក្សាទុកអោយបន្តធ្វើអាជីវកម្មលើមូលដ្ឋានមានកិច្ចសន្យាច្បាស់លាស់ ពីភាគីផ្គត់ផ្គង់ឈើ ដោយអនុលោមតាមផែនការដកហូតឈើសំរាប់ធ្វើអាជីវកម្មប្រចាំឆ្នាំរបស់ក្រុមហ៊ុនព្រៃសម្បទានស្របច្បាប់ ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៤ :** រាល់អាជីវកម្មរបស់រោងចក្រ រោងម៉ាស៊ីនអារឈើ ដែលមិនផ្សារភ្ជាប់នឹងក្រុមហ៊ុនព្រៃសម្បទានស្របច្បាប់ ត្រូវហាមឃាត់ជាដាច់ខាត ។

**ប្រការ ៥ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតាមដានត្រួតពិនិត្យអោយបានត្រឹមត្រូវចំពោះការកាប់ឈើក្នុងអត្រាអតិបរមា ២០ % នៃផលិតផលឈើប្រចាំឆ្នាំរបស់ក្រុមហ៊ុនព្រៃសម្បទាន សំរាប់បំរើដល់ការផ្គត់ផ្គង់ឈើនៅក្នុងប្រទេស ។

**ប្រការ ៦ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងដេប៉ូលក់ឈើ និងអនុផលព្រៃឈើទូទាំងប្រទេស តាមរយៈការត្រួតពិនិត្យ និងការកំណត់បរិមាណផ្គត់ផ្គង់ និងសន្និធិឈើ និងអនុផលព្រៃឈើ នៅតាមដេប៉ូលក់ឈើនីមួយៗ ព្រមទាំងការត្រួតពិនិត្យអោយដេប៉ូឈើទាំងអស់លក់ឈើ ឬ អនុផលព្រៃឈើដែលមានប្រភពស្របច្បាប់ ចេញពីព្រៃសម្បទាន ។

**ប្រការ ៧ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចធ្វើសារាចរណែនាំលំអិតអំពីការអនុវត្តន៍សេចក្តីសំរេចនេះ ។

**ប្រការ ៨ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋាន គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

បាត្តលេខា និងត្រា

ហ៊ុន សែន

***